# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បរណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បរណ្ណាធិការ ផ្នែកដំណឹងសាសនាៈ ព្រះគ្រូសុវណ្ណញ្ញាណ ស្វា-ហ៊ុយ
ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ


| ផ្នែកអក្សរសាស្ត្រ | បញ្ជីរឿង | ទំព័រ |
|---|---|---|
| លោក ហ្វ្រង់ស្វា ម៉ាទីនី ទីប្រឹក្សា ក្រសួងធម្មការ | ពាក្យពន្យល់សេចក្ដីផ្សេងគ្នា ក្នុងរឿងរាមា-យណៈខ្មែរ ............................ | ៣២១ |
| លោក ភិយ-ប៊ុក សមុហបញ្ជីធំ | សេចក្ដីកត់សំគាល់របស់អ្នកប្រែ ............ | ៣២៦ |
| អ្នកឧកញ៉ាវិបុលរាជសេនា(នូ-កន) | រឿងសាមកុក (តមក) ................ | ៣២៧ |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម | ប្រវត្តិសាស្ត្រសង្ខេបប្រទេសចិន (តមក)...... | ៣៣៩ |
| លោក ភិយ-ប៊ុក សមុហបញ្ជីធំ | រឿង ស៊ុន-យ៉ាត់-សេន (តមក-ចប់)....... | ៣៤៥ |

| ផ្នែកសាសនា | | |
|---|---|---|
| ព្រះសគព្រះវិរទ្ធញ្ញាណ | | |
| សោម-ឡុច ក្រុមជំនុំព្រះត្រៃបិដក | មធុរភាសិត............................. | ៣៥៣ |
| ព្រះគ្រូពោធិវង្សាចរិយាពិទូ | | |
| រាជ-កឹង | ពិធីទក្ខិណានុប្បទាននឹងកម្មវិធីព្រះសពសម្ដេច . | ៣៦៨ |
| យសសិរិមេធី ស្រី-អ៊ុ | ប្រវត្តិនិងពិធីបូជាព្រះសព សោម-ឡុច........ | ៣៧៧ |
| ព្រះវិន័យធម្ម យូរ-ប៉ុណ្ណ | ចក្កធម្ម ...................................... | ៣៨៧ |


ឆ្នាំទី ២០ — លេខ ៤ ខែ ឧសភា ឆ្នាំ ១៩៤៨ — ដំឡៃផ្សារ ១ ឆ្នាំ ៦៧ រៀល ។

CHINE FRANÇAISE RÉGIE

# ចក្កធម៌

## របស់ព្រះវិន័យធម្ម យូរ-ប៊ុណ្ណ

### នៅវត្តចណ្ណាលោចជាក្រុមជំនុំព្រះត្រៃបិដកនៅពុទ្ធសាសនបណ្ឌិត្យ

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

តពីនមស្សការនេះទៅ ខ្ញុំនឹងលើកយកចក្កធម៌មកសំដែងក្នុងទីនេះ ដើម្បីជាទីសវនាការដល់អស់លោកអ្នកជាពុទ្ធបរិស័ទទាំងឡាយ ដូចតទៅនេះ

ចក្កធម៌ ធម៌ដូចជាកង់រមែងវិលទៅកាន់សេចក្ដីចំរើនមាន ៤ យ៉ាងគឺ

១- បដិរូបទេសវាសៈ នៅក្នុងប្រទេសដ៏សមគួរ

២- សប្បុរិសូបសំសេវៈ សេពគប់នឹងសប្បុរស

៣- អត្តសម្មាបណិធិ តាំងខ្លួនបានដោយប្រពៃ

៤- បុព្វេកតបុញ្ញតា ភាពជាអ្នកបានធ្វើសេចក្ដីល្អទុកមកពីក្នុងកាលមុន ។

ធម៌ ៤ យ៉ាងនេះ ព្រះពុទ្ធជាម្ចាស់ទ្រង់សំដែងប្រៀបដូចជាចក្ក, ធម្មតាចក្ក ឬរថ កាលបើបុគ្គលមានបំណងបរទៅកាន់ទីណាមួយហើយ រមែងនាំទៅកាន់ទីនោះបានតាមប្រាថ្នា យ៉ាងណាមិញ ធម៌ ៤ យ៉ាងនេះបើបុគ្គលបានប្រព្រឹត្ត បានធ្វើឲ្យសមហេតុសមផលហើយ ក៏រមែង

ធ្វើសេចក្ដីចំរើនឲ្យកើតឡើងដោយលំដាប់តាមជាន់តាមថ្នាក់បាន ក៏យ៉ាងនោះដែរ ។ សូមលើកយកឧបក្កធម៌ទី ១ មកសំដែងតទៅ គឺ :

១ · បដិរូបទេសវាសៈ ប្រែថា នៅក្នុងប្រទេសដ៏សមគួរនោះ គឺប្រទេសណាដែលសម្បូណ៌ដោយអ្នកប្រាជ្ញចេះដឹងច្រើន ប៉ិនប្រសប់ខាងការរៀបចំប្រជាជាតិឲ្យសិក្សាចំណេះវិជ្ជា និងធម៌អាថ៌ផ្លូវព្រះពុទ្ធ-សាសនាជាគ្រឿងប្រដៅចិត្តឲ្យមានមេត្តាករុណាធម៌ ចេះសង្គ្រោះគ្នា ចេះស្រឡាញ់រាប់អានគ្នា ចែកសេចក្ដីសុខដល់គ្នា ប្រាប់ប្រយោជន៍ដល់គ្នា ដើម្បីញ៉ាំងប្រជាជាតិជាមួយគ្នាឲ្យថ្កុំថ្កើងក្នុងការចេះដឹង, ប្រទេសយ៉ាងនេះ ហៅថាប្រទេសដ៏សមគួរ ជាប្រទេសប្រកបដោយធម៌ ។

មួយទៀត ប្រទេសណា មានព្រះមហាក្សត្រសោយរាជ្យប្រកបដោយទសពិធរាជធម៌ បានដឹកនាំការតាមប្រវេណីរបស់ព្រះមហាក្សត្រទ្រង់ធម៌ មានសេចក្ដីអនុគ្រោះដល់ប្រជាករស្ត្រ រៀបចំប្រជាជាតិឲ្យសិក្សាចំណេះវិជ្ជាទាំងផ្លូវលោកនិងផ្លូវធម៌ឲ្យគ្រប់គ្រាន់និវិជ្ជាអក្សរសាស្ត្រលេខនព្វន្ត និងសិល្បកម្មផ្សេងៗ សម្បូណ៌ទៅដោយស្រែចម្ការច្បារដំណាំ ទាំងបរទេសផ្លូវសេដ្ឋកិច្ច ពាណិជ្ជកម្ម កសិកម្ម និងសម្បូណ៌ដោយ ស្ពាន ថ្នល់ ព្រែក ទន្លេ សម្រាប់អ្នកដែលត្រូវការមានការបង្ហូរទឹកចេញចូលដាក់ស្រែចម្ការច្បារដំណាំជាដើម ព្រមទាំងគ្រឿងប្រើប្រាស់

គ្រឿងបរិភោគ ឧបភោគ គ្រឿងស្លៀកពាក់ និងគ្រឿងការពារសត្រូវ ជាដើម; យ៉ាងនេះហៅថា ប្រទេសដ៏សមគួរតាមផ្លូវលោក ។

ទាំងប្រជាជាតិដែលមានភក្តីសំណាក់ស្នាមកកើតចួបប្រទះនឹងសេចក្តីសុខ-ចំរើន ក្នុងប្រទេសដែលសម្បូណ៌ដោយចំណេះវិជ្ជា ភោគសម្ប័ទ ដូចបានពោលហើយខាងលើនេះទៀតសោត គឺត្រូវតែកសាងកំឡាំងកាយ វាចា ចិត្តឲ្យរឹងប៉ឹង តាំងសេចក្តីព្យាយាមកាប់បំបាត់និស្ស័យជាខាតាប ខ្ជិលច្រអូសធុញទ្រាន់ ប្រមាទមើលងាយនោះចោលចេញ ហើយផ្គងកាយ វាចា ចិត្តឲ្យរឹងប៉ឹង ក្រៀវក្លាមានខន្តិ មានឧបាយសង្កត់ធ្ងន់ទ្រាំទ្រតស៊ូប្តូរនឹងកិច្ចធុរៈការងារគ្រប់យ៉ាង ឲ្យផុះផាល លូតលាស់ចំរើនឡើង ដើម្បីនឹងបង្ហិលភក្តីសំណាក់ស្នាជាគតាបនោះ ឲ្យវិលទៅកាន់សេចក្តីចំរើន កុំបណ្តោយភក់ស្នាទៅតាមអំពើចិត្ត កុំផេតចាំព្រេងសំណាងនោះមិនបានទេ ឯព្រេងសំណាងដែលនឹងផ្តល់ឲ្យនោះ លុះតែខំប្រឹងរៀនប្រឹងរក ប្រឹងប្រព្រឹត្ត ទើបដោះកក់ស្នានឹងផ្តល់ឲ្យតាមលំដាប់ខ្ពស់ទាប; យ៉ាងនេះហៅថា នៅក្នុងប្រទេសដ៏សមគួរ ។

ប្រទេសនីមួយៗ ដែលនឹងលូតលាស់ចំរើនឡើងទៅកាន់ឋានៈជាន់ខ្ពស់បាន, លុះតែប្រកបដោយផ្លូវទាំងពីរយ៉ាង គឺផ្លូវលោក និងផ្លូវធម៌ អាស្រ័យគ្នា ប្រព្រឹត្តទៅជាមួយគ្នា ដើរទៅទន្ទឹមគ្នា: ទើបអាចនឹងចំរើនរុងរឿងសុខក្សេមក្សាន្តបាន ។ ផ្លូវទាំងពីរនេះតែងដើរទៅជាមួយ ផ្លូវ

លោកនៅត្រង់ណា ផ្លូវធម៌ក៏នៅត្រង់នោះ, ផ្លូវធម៌នៅត្រង់ណា ផ្លូវលោកក៏នៅត្រង់នោះដែរ, ផ្លូវលោកស្ថិតនៅផ្នែកណា ផ្លូវធម៌ក៏ស្ថិតនៅផ្នែកនោះដែរ ។ បើមានតែផ្លូវធម៌ម្យ៉ាង មិនមានកិច្ចការរៀបចំឲ្យមានគ្រឿងការពារប្រទេស និងសម្បត្តិរបស់ប្រទេសទេ, ប្រទេសក៏នឹងក្លាយទៅជាក្រីក្រលំបាកទៅជាព្រៃផ្សៃ ទៅជាប្រទេសមិនមានតម្លៃទៅវិញ ។ ឬក៏មានតែផ្លូវលោកម្យ៉ាង ប្រទេសក៏នឹងក្លាយទៅជាភ្លើងឆេះពេញលោកទាំងមូល, ព្រោះមនុស្សប្រកបដោយលោភៈ ទោសៈ មោហៈ ច្រើន មិនមានមេត្តាករុណាធម៌សម្រាប់លត់ភ្លើង គឺ លោភៈ ទោសៈ មោហៈ នោះឡើយ ។

ព្រះពុទ្ធជាម្ចាស់ទ្រង់ឈ្វេងយល់ហេតុផលនេះហើយ ទើបទ្រង់សំដែងផ្លូវទាំងពីរប្រការនេះឲ្យសត្វធ្វើតាម ប្រព្រឹត្តតាម, ដើម្បីនឹងញុំាងប្រទេសទាំងមូលឲ្យដើរទៅកាន់សេចក្ដីសុខ-ចំរើនតទៅ ។

ការដែលអាស្រ័យនៅក្នុងប្រទេសដ៏សមគួរដូចបានពោលមកនេះ រាប់ជាមង្គល ១ យ៉ាងប្រសើរក្នុងលោក ហៅថាចក្កធម៌ ១ ។

ទី ២- សប្បុរិសូបសំសេវៈ: សេចក្ដីគប់នឹងសប្បុរសមានសេចក្ដីថា បណ្ដាមនុស្សក្នុងលោក សូម្បីមានកំឡាំងកាយ កំឡាំងប្រាជ្ញា កំឡាំងគំនិត សម្រាប់ចិញ្ចឹមជីវិតរបស់ខ្លួននឹងអ្នកដទៃ, ឬឲ្យសម្រេចប្រយោជន៍ដល់ក្រុមញាតិសាច់សាលោហិត រហូតដល់

ប្រទេសជាតិ មិនឲ្យវិនាសអន្តរាយ ទាំងធ្វើឲ្យភាពមារយាទឲ្យល្អកើតឡើងបាននោះ គឺត្រូវតែធ្វើសេចក្តីសិទ្ធសាធារណៈសេពគប់នឹងសប្បុរសជាមុន ដើម្បីនឹងឲ្យស្គាល់ហេតុផលទំនងការនោះសិន ទើបកិច្ចការនោះដើរទៅកាន់សេចក្តីសុខ-ចំរើនបាន ។

ឯបុគ្គលជាសប្បុរសនោះមិនកំណត់រូបណាមួយឡើយ ទោះបីបុរស, ស្ត្រី, គ្រហស្ថ, បព្វជិត ឲ្យតែមានចរិយាល្អ ឋិតនៅក្នុងធម៌របស់សប្បុរស ឈ្មោះសក់នីវៃប៉ុន ប្រសប់ចេះដឹងផ្លូវលោកផ្លូវធម៌បរិបូណ៌ ក៏ហៅថាសប្បុរសទាំងអស់ ។ សប្បុរសនេះជាបុគ្គលថ្លៃថ្លាក្នុងលោក អាចយកចិត្តទុកដាក់ជួយស្រោចស្រង់ដោះទុក្ខប្រជាជាតិមាតុភូមិ ឲ្យឡើងទៅកាន់ថ្នាក់ជាន់ខ្ពស់បាន ។

ហេតុនេះ យើងជាអ្នកស្រឡាញ់សេចក្តីសុខ-ចំរើន ត្រូវតែផ្ចិតចំឡើយយកបែបបទសណ្ដាប់ធ្នាប់ ការចេះដឹងពីលោកឲ្យបានគ្រប់គ្រាន់តាមសម័យ កុំបង្អង់ឲ្យពេលវេលាកន្លងពីយើងទៅ ដើម្បីសាងជាតិឲ្យរឹងជំហរមាំមួន លើកខ្លួនឲ្យផុតពីភាពជាទាបដែលបានទទួលគ្រោះថ្នាក់នៃសេចក្តីល្ងង់ខ្លៅក្រីក្រលំបាកពោលពេញ ។

មួយទៀត សប្បុរសនេះ បើនរណាបានចូលទៅជួបគប់ប្រសប់យកជាមិត្ត ឬសូមធ្វើជាគ្រូជាអាចារ្យ ហើយខំស្ដាប់រៀនសូត្រប្រតិបត្តិតាម បើទុកជាមិនធ្លាប់ជាបណ្ឌិតមកពីដើម ក៏គង់ក្លាយទៅជា

បណ្ឌិតតាមលោកមិនលែង ព្រោះលោកនោះឯង តែងមានឧបាយចេះនិយាយតែណែនាំអ្នកដែលចូលទៅសេពគប់នឹងលោកនោះ ឲ្យប្រព្រឹត្តតាមផង ។

សប្បុរសមានគុណគឺសេចក្ដីល្អគ្រប់ការ មានឧបមាដូចគ្រឿងក្រអូបមានក្រស្នា និងកម្រែងផ្កាជាដើម ឯអ្នកដែលចូលទៅគប់ប្រសប់ ដូចជាស្លឹកឈើឬសំពត់ដែលខ្ចប់ដែលរុំគ្រឿងក្រអូបនោះ ព្រោះបើស្លឹកឈើ ឬសំពត់នោះមិនមានក្លិនក្រអូប ក៏ក្លាយទៅជាមានក្លិនក្រអូបតាម សេចក្ដីនេះ សមដូចពុទ្ធភាសិតថា

តគ្គរញ្ច បលាសេន យោ នរោ ឧបលិម្បតិ
បត្តាបិ សុរភី វាយន្តិ ឯវំ ធីរូបសេវនា ៖

សេចក្ដីថា នរជនណារុំខ្ចប់ខ្លឹមក្រស្នាដោយស្លឹកឈើ បើទុកជាស្លឹកឈើ (មិនធ្លាប់ក្រអូបពីដើម) ក៏គង់តែក្លាយទៅជាក្រអូបឈ្ងុយឈ្ងប់គួរឲ្យពេញចិត្ត យ៉ាងណាមិញ ការដែលចូលទៅសេពគប់នឹងលោកអ្នកប្រាជ្ញ (ក៏មានកិត្តិសព្ទក្រអូបខ្ចរខ្ចាយ) ក៏យ៉ាងនោះដែរ ។

សប្បុរសនេះ លោកមិនមែនពន្យល់ប្រាប់តែផ្លូវសុខសួគ៌និព្វាន ដែលយើងមើលមិនឃើញនោះទេ គឺលោកបង្ហាញផ្លូវបច្ចុប្បន្នដែលមើលឃើញជាក់ស្ដែងនឹងភ្នែកផង ដូចជាពន្យល់ឲ្យរៀនចំណេះវិជ្ជា ឲ្យប្រឹងប្រែងរកទ្រព្យសម្បត្តិ កុំឲ្យសេពគប់នឹងបុគ្គលពាលដូច្នេះជាដើម ។

ព្រោះហេតុនោះ សាធុជនទាំងឡាយ កាលបើបានជ្រាបសេចក្តីដែលបានពោលហើយខាងលើនេះ គួរសេពគប់នឹងសប្បុរសចំណែកមួយពុះ កុំសេពគប់នឹងបុគ្គលពាលជាដាច់ខាត, បើប្រទេសយើងទាំងមូលមិនមានសប្បុរសម្នាក់សោះ មានសុទ្ធតែមនុស្សពាល ក៏កុំគប់ប្រសប់ឡើយជាដាច់ខាត ។

ការសេពគប់នឹងសប្បុរស ដូចបានសំដែងហើយខាងលើនេះ រាប់ជាជាបក្ខធម៌ទី ២ ។

ទី ៣- អត្តសម្មាបណិធិ ប្រែថា ការតាំងខ្លួនបានដោយប្រពៃនោះគឺបុគ្គលកាលបើបានសេពគប់នឹងសប្បុរស បានសិក្សារៀនចំណេះវិជ្ជា ផ្ចិតចិត្តឡើងយកតែបែបបទសណ្តាប់ធ្នាប់ពីលោកបានហើយ ត្រូវផ្តាច់ចិត្តនិស្ស័យថោកទាបគឺគំនិតចាស់ដែលធ្លាប់កាន់ ធ្លាប់ជឿ ធ្លាប់ប្រព្រឹត្ត ធ្លាប់ខ្វល់ប្រមូល ធុញទ្រាន់ ធ្វេសប្រហែសនោះចោលចេញ ហើយស្រាវជ្រាវរោបចាប់យកនិស្ស័យជាន់ខ្ពស់ ដែលបានសន្សំអប់រំនោះមកដាក់តម្កល់ក្នុងដួងចិត្តរបស់ខ្លួន, ដើម្បីនឹងសាងអត្តភាព និងប្រទេសជាតិមាតុភូមិ ឲ្យឡើងទៅកាន់ការរុងរឿងជាន់ខ្ពស់, យ៉ាងនេះហៅថា ការតាំងខ្លួនបានដោយប្រពៃ ។

ឯគ្រោងការដែលកសាងអត្តភាព និងប្រទេសជាតិមាតុភូមិ ឲ្យឡើងទៅកាន់ការរុងរឿងជាន់ខ្ពស់នោះ សំដៅយកប្រយោជន៍ពីរប្រការ គឺ

ប្រយោជន៍ដែលត្រូវបានឃើញទាន់ក្នុងជាតិនេះ ហៅថា ទិដ្ឋធម្មិក-ប្រយោជន៍ ១ ប្រយោជន៍ដែលត្រូវបានក្នុងកាលខាងមុខ ហៅថាសម្បរា-យិកប្រយោជន៍ ១ ។

ទិដ្ឋធម្មិកប្រយោជន៍ ជាហេតុឲ្យបានសេចក្ដីសុខ ចំរើនក្នុងជាតិនេះអស់មួយជីវិត, ចែកចេញជា ៤ យ៉ាងគឺ :

១- ការបរិបូណ៌ដោយសេចក្ដីព្យាយាមប្រឹងប្រែងប្រកបកិច្ចការដើររកស៊ីចិញ្ចឹមជីវិតដោយកិច្ចដែលត្រូវធ្វើផ្សេងៗ ទាំងចំណេះវិជ្ជាគ្រប់បែប ដរាបដល់បានភោគសម្បទ៍ដែលជាផលកើតមកអំពីហេតុនៃសេចក្ដីខ្នាតប្រកបការងារនោះៗ ហៅថាឧដ្ឋានសម្បទា ។

២- ការបរិបូណ៌ដោយការបីបាច់រក្សាថែទាំទ្រព្យសម្បត្តិដែលខំរកបានមកនោះ មិនឲ្យខូចខាតអន្តរាយដោយហេតុមិនគួរនឹងអន្តរាយ មានអបាយមុខជាដើម ហៅថាអារក្ខសម្បទា ។

៣- ការចេះចាយវាយទ្រព្យសម្បត្តិចិញ្ចឹមជីវិតល្មមសមគួរដល់កំឡាំងនៃទ្រព្យដែលរកបាន មិនតឹងពេក មិនកញ្ចះកញ្ចាយខ្ជូលាយដៃពេក, ហៅថា សមជីវិតា ។

៤- ការសេពគប់នឹងកល្យាណមិត្រ គឺមិត្រដែលប្រព្រឹត្តត្រឹមត្រូវល្អដោយកាយ វាចា ចិត្ត, ហៅថាកល្យាណមិត្តតា ។

ទាំង ៤ យ៉ាងនេះ ហៅថាទិដ្ឋធម្មិកប្រយោជន៍ ជាប្រយោជន៍បច្ចុប្បន្ន ។

ឯសម្បរាយិកប្រយោជន៍ ជាប្រយោជន៍ដែលបានក្នុងកាលខាងមុខ ឬពេលមុខនោះ ក៏បែកជា ៤ យ៉ាងដែរ គឺ :

១ - ការបរិបូណ៌ដោយសទ្ធា គឺជំនឿចំពោះតែរឿងដែលគួរជឿ មានជឿថា ធ្វើអាក្រក់បានអាក្រក់ ធ្វើល្អបានល្អ និងការជឿគុណព្រះរតនត្រ័យជាដើម. យ៉ាងនេះហៅថាសទ្ធាសម្បទា ។

២ - ការបរិបូណ៌ដោយការរក្សាកាយ វាចា ចិត្តឲ្យតបសា មិនឃ្មើសឃ្មុន មិនបៀតបៀនសត្វដទៃ មិនលួចដណ្ដើមយកទ្រព្យសម្បត្តិអ្នកដទៃ ដែលគេមិនបានឲ្យដោយកាយ វាចា ចិត្ត មិនលួចកូនប្រពន្ធគេ មិននិយាយពាក្យកុហកបោកប្រាស់យកទ្រព្យគេ មិនត្រូវផឹកនូវទឹកស្រវឹង គឺមានចរិយាបុគ្គលល្អ គួរឲ្យអ្នកដទៃស្រឡាញ់ចូលចិត្ត ចង់គោរពបូជា យ៉ាងនេះហៅថា សីលសម្បទា ។

៣ - ការបរិបូណ៌ដោយការតាំងចិត្តករុណាចំពោះអ្នកកំសត់ទុគ៌ត ហើយលះបង់ទ្រព្យសម្បត្តិចែកចាយឲ្យតាមមានតាមបាន ដល់អ្នកសមុទ្រនិងការបូជាគុណមាតាបិតាជាដើម យ៉ាងនេះ ហៅថា ចាគសម្បទា ។

៤ - ការបរិបូណ៌ដោយការសិក្សារៀនសូត្រ ឬស្ដាប់ពាក្យប្រៀនប្រដៅ ដើម្បីឲ្យកើតប្រាជ្ញាចេះពិចារណា ស្គាល់គុណទោស ស្គាល់ខុសត្រូវ ស្គាល់ល្អអាក្រក់ ស្គាល់ហេតុផល ស្គាល់សេចក្ដីវិនាសនិងចំរើនឬពិចារណាសង្កេតឲ្យឃើញថា ធម្មជាតិគ្រប់យ៉ាង ជារបស់មិនទៀងជាដើម, យ៉ាងនេះ ហៅថា បញ្ញាសម្បទា ។

សម្បទា ៤ យ៉ាងនេះ ហៅថា សម្បរាយិកប្រយោជន៍ជាប្រយោជន៍ដែលយើងត្រូវសន្សំទុកទៅបរលោក ឬក៏ទៅអនាគត ។

ប្រយោជន៍ទាំងពីរប្រការដូចបាននិយាយមកនេះ បើជនណាបានធ្វើបានសន្សំហើយ ជននោះឈ្មោះថាបានគាំទ្រខ្លួនបានដោយប្រពៃ រមែងវិលទៅកាន់សេចក្ដីសុខ-ចំរើនតាមប្រាថ្នា រាប់ថាជាមង្គលមួយយ៉ាងប្រសើរ ហៅថាចក្កធម៌ ៣ ។

ទី ៤ - បុព្វេកតបុញ្ញតា ភាពជាអ្នកបានធ្វើសេចក្ដីល្អទុកមកពីកន្លងកាលមុន ។ សេចក្ដីថា ជនជាតិនីមួយៗ ដែលមានភោគៈសម្បត្តិ យសស័ក្តិ រូបរាងសណ្ឋានទ្រង់ទ្រាយល្អ ឬថ្កុំថ្កើងយ៉ាងណា ក៏សុទ្ធតែមកអំពីកិច្ចសំណាងនិស្សា បានអប់រំសន្សំទុកមកពីកន្លងកាលមុន បើយើងធ្វើយ៉ាងណា ប្រព្រឹត្តយ៉ាងណា សិក្សាយ៉ាងណា ទោះបីតិចច្រើនក្ដី ផលនឹងត្រឡប់ឲ្យផលវិញ ក៏រមែងនឹងទាញបន្ទិលឲ្យតាមគំរូដើម មិនខុសហេតុខុសផលឡើយ ។ សូមទាញឧទាហរណ៍ឲ្យឃើញហេតុ

ផលកម្មនិងបុញ្ញនេះថា ព្រះពុទ្ធជាម្ចាស់ក្តី ព្រះបច្ចេកពុទ្ធក្តី អគ្គសាវកក្តី ឬក៏ព្រះអរហន្តអង្គឯទៀតៗក្តី ដែលទ្រង់បានត្រាស់ជាព្រះពុទ្ធ ជាព្រះអរហន្ត លះកាត់កិលេសបាបទៅកាន់ព្រះនិព្វាន ហើយមានឈ្មោះថាជាអ្នកប្រាជ្ញយ៉ាងឯកក្នុងលោកនោះ ក៏អាស្រ័យមកអំពីបុណ្យកុសលដែលបានធ្វើសាងសន្សំទុកមកពីមុនៗ ប៉ុន្នោះ ដូចយ៉ាងនឹងស្រុកដែនមានព្រះរាជា និងពួកអស់លោកនាហ្មឺនសព្វមុខមន្ត្រីធំតូចគ្រប់ដំណែងដែលទ្រង់បានឡើងទៅកាន់តំណែងជាន់ខ្ពស់ កណ្ដាលទាបបានយ៉ាងនេះ ក៏អាស្រ័យមកអំពីបានសិក្សារៀនសូត្រពីកាលដើម តាមជាន់តាមថ្នាក់ ទើបអាចនឹងឡើងទៅកាន់តំណែងនោះៗបាន, មិនមែនចេះតែទៅកាន់ថ្នាក់នោះឯងៗបានឡើយ ។ អ្នកមានសម្បត្តិ អ្នកខ្សត់ទ្រព្យសម្បត្តិក៏ដូចគ្នា, លុះតែខំប្រឹងរក ប្រឹងធ្វើទុកពីកាលដើម, ទើបសម្រេចផលប្រយោជន៍ទៅបាន ។ ដូចជាកិច្ចសង្គ្រោះគ្នាក្នុងបុញ្ញនេះ គេជួយធ្វើយើង យើងត្រូវជួយធ្វើគេវិញ, គេឲ្យយើង យើងក៏ត្រូវឲ្យគេវិញ ។ សមដូចពុទ្ធភាសិតមួយដែលថា បូជកោ លភតេ បូជំ វន្ទកោ បដិវន្ទនំ បុគ្គលអ្នកបូជាគេ រមែងបានការបូជាមកវិញ អ្នកគំនាប់គាប់គួរគេ រមែងបានទទួលការគំនាប់គាប់គួរមកវិញ ។

សេចក្ដីដែលបានសំដែងមកប៉ុណ្ណោះនេះ ដើម្បីនឹងទាញឲ្យឃើញថា សេចក្ដីល្អដែលយើងបានធ្វើទុកមកពីក្នុងកាលមុនយ៉ាងណា ផលមកខាងក្រោយ ក៏រមែងឲ្យផលយ៉ាងនោះដែរ ។ ព្រោះហេតុនោះ បានជាព្រះពុទ្ធជាម្ចាស់ទ្រង់សំដែងថា ភាពជាអ្នកធ្វើសេចក្ដីល្អទុកមកពីក្នុងកាលមុននោះ ហៅថាជាចក្រមួយ រមែងវិលទៅកាន់សេចក្ដីសុខ-ចំរើនក្នុងលោក គឺថាជាចក្រធម៌ទី ៤ ។

ហេតុនេះ សូមអស់លោក-អ្នកទាំងឡាយគួរតែនាំគ្នាដាក់ច្បាំងតាំងសេចក្ដីព្យាយាមឲ្យរឹងប៉ឹងប្រឹងប្រែតិបត្តិតាមចក្រធម៌ទាំង ៤ យ៉ាងនេះ ទើបចក្រធម៌អាចវិលទៅកាន់សេចក្ដីចំរើនឲ្យទាន់ពេលទាន់សម័យ គឺថាញុំាងព្រះពុទ្ធសាសនានិងប្រទេសជាតិ មាតុភូមិរបស់យើងឲ្យលឿនទៅមុខ កុំបណ្ដោយតាមព្រេងសំណាងស្រុកទេសនោះឡើយ, បើយើងមិនប្រឹងទេ ព្រះពុទ្ធសាសនានិងប្រទេសជាតិក៏នឹងសាបសូន្យទៅពុំខាន ។

សំដែងអំពីចក្រធម៌ ៤ យ៉ាង ចប់តែប៉ុណ្ណោះ ។

ទីបំផុតធម្មទេសនានេះ សូមផ្សាយកុសលបុញ្ញាភិសង្សដល់អស់លោក-អ្នកទាំងឡាយនៅក្នុង[illegible]ទាំងមូល ឲ្យបានសេចក្ដីសុខ-ចំរើនគ្រប់ប្រការ ។

ពុទ្ធានុភាវេន ឧបទ្ទវា ចេ ឧបទ្ទវា

រោគា បេវត្តណយា ច វិនស្សន្តុ អសេសតោ

ដោយអានុភាពនៃព្រះរតនត្រ័យមានពុទ្ធរតនជាដើម បើឧបទ្រព ទាំងរោគ ទាំងទុក្ខភ័យទាំងឡាយ កើតមានហើយក៏សូមឲ្យវិនាសបាត់ទៅ កុំបីនៅមានសេសសល់ឡើយ ( ដោយពុទ្ធទេសនានេះ ) ។

ចប់ បគ្គធមិ